Official Information

# ចុះឈ្មោះបោះឆ្នោត!

## វាចំណាយពេលត្រឹមតែ ៥ នាទីប៉ុណ្ណោះ ដើម្បីប្រាកដថាសំឡេងរបស់អ្នកត្រូវបានឮ

អ្នកចុះឈ្មោះ-អ្នកកត់ត្រា/ក្រឡាបញ្ជីអិលអេខោនធី (RR/CC) មានអ្វីគ្រប់យ៉ាង ដែលអ្នកត្រូវការ ដើម្បីបោះឆ្នោតរបស់អ្នក នៅក្នុង ការបោះឆ្នោតបឋមដោយផ្ទាល់ទូទាំងរដ្ឋនាពេលខាងមុខ! ការចុះឈ្មោះបោះឆ្នោតមាន ភាពងាយស្រួល រហ័ស ហើយអ្នកអាចធ្វើបាន តាមអ៊ីនធឺណិត។

ស្វែងយល់ពីរបៀបដែលអ្នកអាចរៀបចំសម្រាប់ការបោះឆ្នោត និងរៀបចំផែនការបោះឆ្នោតរបស់អ្នក។

## តើខ្ញុំអាចចុះឈ្មោះបោះឆ្នោត ដោយរបៀបណា?

ប្រសិនបើអ្នកបានប្តូរលំនៅដ្ឋានថ្មីៗនេះ នឹង ត្រៀមបោះឆ្នោតជាលើកដំបូង ឬថ្មី នៅក្នុង អិលអេខោនធី អ្នកត្រូវតែចុះឈ្មោះបោះឆ្នោត មុនថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០២៦ ដើម្បីទទួលបានសន្លឹកឆ្នោត តាមសំបុត្រ។

វិធីសាមញ្ញបំផុតក្នុងការចុះឈ្មោះបោះឆ្នោតគឺចូលទៅកាន់ **PLAN.LAVOTE.GOV.**

ប្រសិនបើអ្នកមិនបានចុះឈ្មោះតាមកាលបរិច្ឆេទកំណត់ អ្នកនៅតែអាចចុះឈ្មោះនៅមណ្ឌល បោះឆ្នោតណាមួយ នៅពេលអ្នកទៅបោះឆ្នោត របស់អ្នក។



## កាលបរិច្ឆេទសំខាន់ៗសម្រាប់ការបោះឆ្នោតបឋម ទូទាំងរដ្ឋឆ្នាំ 2026

**ថ្ងៃទី ៣០ ខែមេសា**
ការបោះឆ្នោតតាមសំបុត្រចាប់ផ្តើមមកដល់ ហើយប្រអប់ទម្លាក់សន្លឹកចាប់ផ្តើមបើក

**ថ្ងៃទី ១៨ ខែឧសភា**
ថ្ងៃចុងក្រោយដើម្បីចុះឈ្មោះតាមអនឡាញ ដើម្បីទទួលសន្លឹកឆ្នោត ដែលអាចបោះឆ្នោតបានតាមសំបុត្រ

**ថ្ងៃទី ២៣ ខែឧសភា**
មណ្ឌលបោះឆ្នោតដំបូងបើកសម្រាប់ការ បោះឆ្នោតដោយផ្ទាល់

**ថ្ងៃទី ៣០ ខែឧសភា**
មណ្ឌលបោះឆ្នោតទាំងអស់បើក
ម៉ោង ១០:០០ ព្រឹក - ៧:០០ យប់

**ថ្ងៃទី ២ ខែមិថុនា**
**ថ្ងៃចុងក្រោយនៃថ្ងៃបោះឆ្នោត!**
ម៉ោង ៧:០០ ព្រឹក - ៨:០០ យប់

Official Information

# តើជម្រើសបោះឆ្នោតរបស់ខ្ញុំ មានអ្វីខ្លះ?

អ្នកមានជម្រើសដែលអាចបត់បែនបាន និងងាយស្រួលខាងក្រោម ក្នុងការបោះឆ្នោត របស់អ្នក៖

## ១. ទម្លាក់សន្លឹកឆ្នោតតាមប្រអប់ទម្លាក់ ដែលចាប់ផ្តើម ពីថ្ងៃទី ៣០ ខែមេសា។

សន្សំពេលវេលារបស់អ្នក ហើយរំលងជួររងចាំ! អ្នកអាចបញ្ជូនសន្លឹកឆ្នោតរបស់អ្នក ទៅកាន់ទីតាំងប្រអប់ដាក់សន្លឹកឆ្នោតផ្លូវការមួយ ក្នុងចំណោម ៤០០+ នៅទូទាំងអិលអេខោនធី។ ស្វែងរកប្រអប់ទម្លាក់សន្លឹកឆ្នោត នៅជិតអ្នក នៅ PLAN.LAVOTE.GOV.

## ២. បោះឆ្នោតតាមសំបុត្រ។

សន្លឹកឆ្នោត ត្រូវបានផ្ញើទៅគ្រប់អ្នកបោះឆ្នោត ដែលបានចុះឈ្មោះនៅក្នុងអិលអេ ខោនធី ចាប់ពីថ្ងៃទី ៣០ ខែមេសា។ គ្រាន់តែបំពេញវា ចុះហត្ថលេខាលើស្រោមសំបុត្រ ដែលភ្ជាប់អោយផ្ញើមកវិញ ហើយផ្ញើវាត្រឡប់មកវិញឱ្យបានឆាប់ — យ៉ាងហោចណាស់ ៧ ថ្ងៃ មុនថ្ងៃបោះឆ្នោត។

## ៣. ទៅកាន់មណ្ឌលបោះឆ្នោតណាមួយ

ដែលចាប់ផ្តើម ពីថ្ងៃទី ២៣ ឧសភា។ អ្នកបោះឆ្នោតក្នុងអិលអេខោនធី អាចបោះឆ្នោតរបស់ពួកគេនៅមណ្ឌលបោះឆ្នោតណាមួយ។ ស្វែងរកមណ្ឌលមួយ ដែលនៅជិតអ្នក តាម PLAN.LAVOTE.GOV ហើយរៀបចំផែនការបោះឆ្នោតរបស់អ្នក មុនថ្ងៃបោះឆ្នោត!

